# ជីវិតកូនកសិករ

(បទពាក្យ៧)

អនិច្ចា! វាសនាកូនកសិករ រស់ត្រឹមកំដរទ្វីបលោកីយ៍
មានកាយខ្វះទ្រព្យភ័ព្វអប្រិយ ទទួលតែក្តីទុក្ខខ្លោចផ្សា។
រៀនសូត្យពុំបានតាមចំណង់ ចំណេះខ្វះអង្គខ្វះតម្រា
ធនធានពុំមានតាមត្រូវការ អំពល់ចិន្តាឥតពេលល្ហែ។
ពឹងឪពុកម្តាយលោកក្រក្រី កាប់គាស់ភ្ជួរដីចំការស្រែ
ជំនួយកូនរៀនរាល់ឆ្នាំខែ កាយពុកអ្នកម៉ែស្គមរីងរៃ។
ជូនគ្រប់ជូនខ្វះបំរះខំ ផ្ញើលុយឧបត្ថម្ភកូនពិសី
ទោះខ្លួនតោកយ៉ាកលំបាកក្តី ស៊ូទ្រាំធ្វើហីឥតស្តីថ្លែង។
កូនឃ្លាតមកឆ្ងាយពីគេហា បន្តសិក្សាទាំងចំបែង
ជូនខ្សត់ទ្រាំអត់មិនហ៊ានថែង លាក់ទុក្ខម្នាក់ឯងតាមវាសនា។
ទោះបាយ សម្លម្ជូរត្រកួន ប្រហុកផ្អួនៗឥតរអា
ទ្រាំរស់ដើម្បីការសិក្សា អោយបានថ្លៃថ្លានាថ្ងៃមុខ។
នឹងទារលុយកាក់តាមត្រូវការ នឹកឃើញគ្រួសារសែនជាទុក្ខ
អាសូរព្រះកាយម្តាយឪពុក ខំត្រាចត្រុកៗរកថវិកា។
ខ្លួនក៏ចាស់ៗនឿយហេវហត់ ត្រដរអំណត់ហាលសុរិយា
ញើសដាបជោកកាយគួរអនិច្ចា ឈឺថ្កាត់ម្តេចម្តាឥតត្អូញត្អែ។
កូនសែនខ្លោចចិត្តក្រៃអនេក គេងស្រក់ទឹកភ្នែកនឹកពុកម៉ែ
ពេលមានជម្ងឺនរណាដែរ ជួយព្យាបាលថែបីត្រកង។
កូនធ្មេចភ្នែកទ្រាំបៀមក្រួសថ្ម សិក្សាបន្តយកសំណាង
ខំក្រេបវិជ្ជាជាត្រើយឆ្លង ផុតភពសៅហ្មងសមុទ្រកម្ម។
ឱ! អ្នកមានគុណកូនអាណិត កូននឹងតាំងចិត្តតាមបណ្តាំ
គោរពពាក្យពេចន៍ពុកម៉ែផ្តាំ ដួងចិត្តចងចាំគ្រប់វេលា។
ជីវិតអ្នកក្រកូនស្គាល់ច្បាស់ នឹងខំបំរះប្រឹងស្ទុះស្ទារ
តស៊ូសិក្សាយកវិជ្ជា ធ្វើទុនគាំពារផុតក្រក្រី។
សិក្សាចប់ហើយនឹងវិលវៃ សាងជីវិតថ្មីជូនពុកម៉ែ។✍

(២០ ឧសភា ២០០១)

ភិក្ខុ វណ្ណគុត្តោ ស្វាត សាលឿម